# រឿង សម្លាញ់បីនាក់



ឆ្នាំ ២០១០

សម្លាញ់បីនាក់ឈ្មោះ៖ ម៉ាប់ជាកូនជ្រូក ពាលជាកូនឆ្កែ ចែជាកូនមាន់ រស់នៅយ៉ាងសុខសាន្តក្នុងទីធ្លាចិញ្ចឹមសត្វមួយ។

ថ្ងៃមួយម៉ាប់និយាយទៅកាន់ពាលថា៖

- បងពាលឯងចង់ធាត់ធំមានសុខភាពល្អដូចខ្ញុំដែរឬទេ?

ពាលឆ្លើយ៖

- បាទ ចង់ណាស់ម៉ាប់...តែខ្ញុំមិនដឹងធ្វើដូចម្ដេច?
- ឱស្រួលណាស់ពាលអើយ គឺពាលឯងត្រូវដេក ហូប ហូបឱ្យបានច្រើនជាទីបំផុត។ ឯងដឹងទេថាគ្មានអ្វីធំជាងដំណេក និង ការហូបទេដែលធ្វើឱ្យឯងមានសុខភាពល្អ។



ពេលចប់សម្ដីនេះភ្លាម ម៉ាប់កន្ទាត់ក៏ដេកលង់លក់ទៅ។ ឯពាលកូនឆ្កែវិលមកកន្លែងដើមវិញ។



គាប់ជួនពេលនោះ ចែកូនមាន់ដើរយ៉ាងសង្ហាមកជិត ពាល ដែលកំពុងតែដេកស្លូកស្លឹង ប្លែកពីធម្មតាក៏ទទះស្លាបរងាវមួយបទ យ៉ាងពីរោះរួចសួរថា៖

- នែសម្លាញ់ ឯងឈឺឬ?

- ពាលឆ្លើយ៖ ទេខ្ញុំឥតឈឺទេ ខ្ញុំធ្វើតាមបងម៉ាប់ប្រាប់ទេតើ ព្រោះបងម៉ាប់ថា៖

បើខ្ញុំធ្វើដូចគាត់បាន ខ្ញុំច្បាស់ជាធំធាត់ ដូចគាត់មិនខាន។



- ហាស ហាស ចែសើចរួចពោលថា៖
- នែពាលអើយ ម៉ាប់ជាកូនជ្រូកកន្ទាត់កម្មិលផេះទេតើ ។
ការធំធាត់ និងសុខភាពល្អគឺស្ថិតនៅលើការហាត់ប្រាណ ការសំអាតខ្លួន និងការប្រកាន់ខ្ជាប់នូវពេលគេង ពេលហូបឱ្យបានទៀងទាត់។





ចាប់ពីពេលនោះមក ពាលកូនឆ្កែក៏ធ្វើតាមចៃកូនមាន់ ហើយទទួលបានសុខភាពល្អបរិបូណ៌ និង មានកម្លាំងមាំមួនមិនដូចម៉ាប់កូនជ្រូក ដែលគ្រាន់តែធាត់ហើយគ្មានកម្លាំងកាយនោះទេ។

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
អ្នករៀបរៀង : លោកស្រី ឈុំ សារ៉ានី
វិចិត្រករ : លោក អ៊ុត រឿន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អរ.សសរ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

អំណោយ អ៊ុយនីសេហ្វ
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)
ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០
មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រែសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ
ចំនួន : ៥,០០០ក្បាល
លេខ : CYK N10016
រោងពុម្ព : **J S R C** Printing House

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានអប់រំកុមារតូច**

CYK

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317033